ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៣៣០
ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០០១

**<u>សាលដីកា</u>**

លេខៈ៩០
ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធាន
២-លោក .......... ជាចៅក្រម
៣-លោក ........... ជាចៅក្រមរបាយការណ៍
៤-លោក ............ ជាចៅក្រម
៥-លោក ............. ជាចៅក្រម
៦-លោក ............. ជាចៅក្រម
៧-លោក ............ ជាចៅក្រម
៨-លោក ............. ជាចៅក្រម
៩-លោក ............ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក .............

**<u>តំណាងមហាអយ្យការ</u>**

-ឯកឧត្តម ............. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៦ខែ កក្កដា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ។

- រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ អយ ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ មុខរបរវេជ្ជបណ្ឌិត ទីលំនៅផ្ទះលេខ១៧៤Eoផ្លូវលេខ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមនក្រុងភ្នំពេញ។ ឪពុកឈ្មោះអ៊ុច ឆោម(ស) ម្តាយឈ្មោះ ជាម យី(ស) ប្រពន្ធឈ្មោះ អ៊ុំ បុប្ផា ។

មានមេធាវីលោក ........... ។

- និងម្ចាស់បណ្តឹងសាទុក្ខឈ្មោះកសវណាវ ភេទស្រីអាយុ៤៨ឆ្នាំ ជាតិខ្មែរមុខរបលក់ដូរ មានទីលំនៅផ្ទះលេខ១៧៤Eo ផ្លូវលេខ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ។ ឪពុកឈ្មោះ កែវ ចៅវង្ស (ស) ម្តាយឈ្មោះ ជាម យី(រ) ប្តីឈ្មោះ យឹម ប៊ូណាស្រេង ។

មានមេធាវី លោក ............

អំពីវិវាទ ប្តឹងទាមទារផ្ទះ និងដី

បានឃើញបណ្តឹងសាទុក្ខលេខ៣០១ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០១ របស់លោក អយ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៦ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច ដែលមិនបានសម្រេចអំពីសំណងអន្តរាយ និងការខាតបង់ពេលវេលា និងបណ្តឹងសាទុក្ខលេខ៣០០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០១ របស់អ្នកស្រីកសវណាវ លើត្រង់ចំណុចនៃសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៣០ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី២៨-០៤-៩៤ របស់ឈ្មោះលោក អយ ជាដើមចោទថាខ្លួនប្តឹងទាមទារយកផ្ទះលេខ១៧៤Eo និងដីពីឈ្មោះ កសវណាវ ដោយសំអាងហេតុថា កាលពីឆ្នាំ១៩៧៩ខ្លួនបានមកកាន់កាប់ផ្ទះលេខ១៧៤នេះដោយបានដាដំណាំនិងថែរក្សាដំណាំដែលមានស្រាប់ទៀតផង ។ នៅចុងឆ្នាំ១៩៨០ ពេលខ្លួនត្រឡប់មកពីធ្វើការវិញ ក៏ស្រាប់តែឃើញឈ្មោះកសវណាវ គាស់ទ្វារផ្ទះ ចូលស្នាក់នៅក្នុងបន្ទប់ល្វែងខាងក្រោម ដែលមានបណ្តោយ១៤ម ទទឹង៤ម ។ឈ្មោះនេះ បានសុំខ្លួនស្នាក់ នៅតែ៣ខែប៉ុណ្ណោះ ទំរាំសង្កាត់រកផ្ទះថ្មីឱ្យស្នាក់នៅបាន ។ នៅពេលនោះខ្លួនបានប្តឹងតវ៉ាទៅសង្កាត់តាម រយៈប្រធានមណ្ឌលឈ្មោះ អ្នកស្រីទេព ប៉ានី ហើយអ្នកស្រីបានចុះមកបញ្ជាក់ឱ្យ កសវណាវ សន្យាថា សុំស្នាក់នៅតែ៣ខែទេ ។ ដោយមានការសន្យាច្បាស់លាស់យ៉ាងដូច្នេះ ទើបខ្លួនសុខចិត្តរើតវ៉ាន់ចេញពី ល្វែងនេះ។ ចាប់ពីពេលនេះមកសង្កាត់ក៏មិនឃើញ រកផ្ទះឱ្យឈ្មោះនេះក៏ក្រាញមិនព្រមចេញ ព្រមទាំងបង្ក ទំនាស់និងបំផ្លិចបំផ្លាញផលដំណាំសំភារៈ រហូតដល់ប្រមាថដល់អាយុជីវិតខ្លួនទៀតផង។ នៅដើមខែកុម្ភៈ ឆ្នាំ១៩៩០ ឈ្មោះនេះបានយកកំលាំងយោធាមកដណ្តើមយកផ្ទះរបស់ខ្លួនមួយល្វែងទៀត ដោយមានបណ្តោយ១៤ម ទទឹង៤ម ដោយគាត់កាត់ជន្ទល់ធ្វើអំពីឈើ ហើយរៀបចំជញ្ជាំងធ្វើអំពីឥដ្ឋ ខ័ណ្ឌជាបន្ទប់ និងកាត់ផ្តាច់ទឹកមិនឲ្យខ្លួនប្រើប្រាស់ទៀតផង ។នៅដើមខែមិថុនា ឆ្នាំ១៩៩៣ឈ្មោះ នេះបានយកកម្លាំងមកគំរាម ដល់អាយុជីវិតរបស់ខ្លួនម្តងទៀត ហើយរំលោភសង់ផ្ទះ នៅលើដីចំហៀងខាងត្បូង ដែលមានបណ្តោយ១៤ម ទទឹង៦,៥០ម ព្រមទាំងកាប់បំផ្លាញដំណាំ កាត់ផ្តាច់បំពង់ទឹកស្អាត និងកាត់ផ្តាច់លូបង្ហូរទឹកចោល ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ២០៤ (យ)ចុះថ្ងៃទី២១-១០-៩៨ របស់ក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១- ទទួលពាក្យបណ្តឹងរបស់ឈ្មោះ អយ ចុះថ្ងៃទី១៩-១០-៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ហាមឃាត់ឈ្មោះ កសវណេរ មិនឱ្យលក់ដូរបញ្ចាំ ផ្ទេរសិទ្ធិទៅឱ្យអ្នកដទៃ និងធ្វើមរតកបន្តទៅឱ្យទាយាទ នូវផ្ទះលេខ១៧៤Eo ផ្លូវត្រសក់ផ្អែម ក្រុមទី៣៩ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ទុកជាបណ្តោះអាសន្នសិន រង់ចាំតុលាការសម្រេចដល់រឿងអង្គសេចក្តី ។

៣- បង្គាប់ឱ្យឈ្មោះ អយ បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ បូករួម២០០០៛ ។

បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៨ របស់អ្នកស្រី កសវណេរ ដែលប្តឹងជំទាស់នឹងដីកាសម្រេចតាមពាក្យសុំលេខ០៤(យ) ចុះថ្ងៃទី២១-១០-៩៨ របស់តុលាការក្រុងភ្នំពេញ លើគ្រង់ចំណុចទាំងមូល ។

បានឃើញដីកាកិច្ចការប្រេញាប់លេខ០៣ប្រ.ដ ចុះថ្ងៃទី១១ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៩-១០-៩៨ របស់ឈ្មោះ កែវ សុវណ្ណារុធ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២- ហាមឃាត់ឈ្មោះ កសវណេរ មិនឱ្យលក់ដូរ បញ្ចាំ សាងសង់បន្ថែម, ផ្ទេរសិទ្ធិ ធ្វើអំណោយទានទៅអ្នកដទៃ និងធ្វើមរតកបន្តទៅឱ្យទាយាទនូវផ្ទះលេខ១៧៤Eo ផ្លូវ៦៣ ក្រុម៣៩ សង្កាត់ បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ទុកជាបណ្តោះអាសន្នសិន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី នៃរឿងនេះ ។

៣- បង្គាប់ឱ្យឈ្មោះកសវណេរបង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តីចំនួន១៨០០៛រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ សរុប ២០០០៛ ។

៤- ដីកាសម្រេចនេះ មានអានុភាពភ្លាមៗ ទោះជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

បានឃើញសាលក្រមលេខ២០(គ) ចុះថ្ងៃទី០៧ខែមិថុនាឆ្នាំ១៩៩៩ របស់តុលាការ ក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះអយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិ ច្បាប់ ។

២-ទទួលពាក្យបណ្តឹងតប របស់ចុងចម្លើយឈ្មោះកសវណេរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែត្រូវបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

៣-ប្រគល់ផ្ទះលេខ១៧៤Eo គិតត្រឹមពីសរសេរកណ្តាលនៃផ្ទះ មកផ្នែកខាងជើងដែលស្ថិតនៅផ្លូវលេខ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញទៅឱ្យឈ្មោះកសវណេរ គ្រប់គ្រងជាកម្មសិទ្ធិតាមច្បាប់ចាប់តាំងពីសាលក្រមចូលជាស្ថាពរតទៅ ។ សល់ពីនេះ គិតត្រឹមពីសរសេរកណ្តាល មកផ្នែកខាងត្បូងទល់នឹងរបងផ្ទះត្រូវប្រគល់ទៅឱ្យដើមចោទឈ្មោះ អយ គ្រប់គ្រងតាមច្បាប់ចាប់ តាំងពីសាលក្រមចូលជាស្ថាពរតទៅ ដើមចោទទាមទារលើសពីនេះ ត្រូវបដិសេធចោល ។

៤- បង្គាប់ឱ្យ កសវណរ និងឈ្មោះ អយ រួមគ្នាបង់ប្រាក់ប្រដាប់ក្ដីគឺ ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្ដី ១៨០០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ និងប្រាក់ស៊ើបអង្កេត៥០០០៛ សរុប៧០០០៛ ។ កាលបើហួសបណ្ដឹងឧទ្ធរណ៍ ត្រូវបង់ពន្ធសមាមាត្រ១% លើតម្លៃផ្ទះ និងដី ។

៥- សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដីបើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ១៧(ដ)ចុះថ្ងៃទី១១ខែមិថុនាឆ្នាំ១៩៩៩របស់អ្នកស្រីកែវសុវណ្ណារុជ ដែលប្ដឹងជំទាស់នឹងសាលក្រមលេខ២០(គ) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ១៩៩៩របស់តុលាការក្រុងភ្នំពេញ លើសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៦៥ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្ដីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-០៦-៩៩ របស់ឈ្មោះកែវ សុវណ្ណរុជ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ២០(គ) ចុះថ្ងៃទី០៧-០៦-៩៩ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣- ប្រគល់ផ្ទះលេខ១៧៤Eo ទាំងមូល និងដីចំហៀងផ្ទះ តាមគំនូសក្រហម នៃប្លង់បង្ហាញទីតាំងដីទំនាស់ចុះថ្ងៃទី២៥-០៧-៩២ របស់ការិយាល័យភូមបាល ខណ្ឌចំការមន ឲ្យទៅឈ្មោះកសវណរ កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៤- កាត់ប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍១៣០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ រង្វាន់ដីកាកោះ៥០០០៛ អាជ្ញាធរតុលាការ៥០០០៛ និងបង្គាប់ឱ្យដើមចោទ បង់ពន្ធសមាមាត្រ១% លើផ្ទៃដីទំនាស់ ។

៥- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៥៤២ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៩ របស់លោក អយ ប្ដឹងជំទាស់នឹងសាលដីកាលេខ៧៦៥ចុះថ្ងៃទី១៩ខែតុលាឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសាលដីកាទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ២៣៧ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០០០ របស់ តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១- ទទួលបណ្ដឹងសាទុក្ខលេខ៥៤២ ចុះថ្ងៃទី០៩-១២-៩៩ របស់លោក អយ ទុកជា ត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ៧៦៥ ចុះថ្ងៃទី ១៩-១០-៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១១១ ចុះថ្ងៃទី២១-៣-២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០រៀល ដែលលោក អយ បានបង់នៅជាន់ តុលាការកំពូល គឺៈ

ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩០០០រៀល ហើយតម្រូវ ឱ្យអ្នកស្រី កែវ សុវណ្ណាវុធ សងប្រាក់ចំនួន១៩០០០រៀល នេះទៅលោក អយ វិញ ។

៥- សាលដីកានេះជំនុំជំរះ នៅថ្ងៃទី២១ខែវិច្ឆិកាឆ្នាំ ២០០០និង ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០០ ។

សាលដីកានេះ ត្រូវបាន តុលាការកំពូល បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១១១ ចុះថ្ងៃទី២១-០៣-២០០០ ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៤(ឈ) ចុះថ្ងៃទី២៩ខែមីនាឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលជំនុំជំរះរឿងក្តីនេះ សារជាថ្មីឡើងវិញ តាមអំណាច សាលដីកាលេខ២៣៧ចុះថ្ងៃទី២១-១១-២០០០ របស់តុលាការកំពូល ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២០(គ) ចុះថ្ងៃទី០៧-០៦-៩៩ របស់តុលាកាក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-ប្រគល់ដីផ្នែកខាងមុខផ្ទះលេខ១៧៤$E_0$គិតត្រឹមអក្សសរកណ្តាលផ្ទះ មកផ្នែកទិសខាង ជើង ស្របតាមផ្ទះល្វែងដែលតុលាការក្រុងភ្នំពេញ បានសម្រេចឱ្យទៅអ្នកស្រី កសវណាវ គ្រប់គ្រងឱ្យ ទៅអ្នកស្រី កែវ សុវណ្ណវុធ ជាម្ចាស់កម្មសិទ្ធិ។

៤-ប្រគល់ដីចាប់ពីអក្សសរកណ្តាល នៅផ្នែកទិសខាងត្បូងគិតទាំងដីនៅក្រោមផ្ទះ១៧៤$E_1$ និងផ្នែកខាងមុខផ្ទះផង រហូតដល់របងដីឡូតិ៍ ផ្នែកខាងត្បូងឱ្យទៅលោកអយគ្រប់គ្រងជាកម្មសិទ្ធិ ។

៥- បង្គាប់ឱ្យលោក អយ ពីដណ្តើររចាស់ចេញ និងឱ្យឈ្មោះនេះ ធ្វើដណ្តើរឡើងផ្ទះលេខ១៧៤$E_1$ នៅពីមុខផ្ទះ១៧៤$E_0$ផ្នែកខាងត្បូងក្នុងដីដែលតុលាការចែកឱ្យវិញ និងបង្គាប់ឱ្យអ្នកស្រី កសវណាវ រុះរើសំណង់របស់ខ្លួន ដែលសង់នៅលើដីរបស់លោកអយ ចេញ ។

៦-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងមេធាវី របស់ដើមចោទ កំបាំងមុខចុងចម្លើយ និងមេធាវី របស់ឈ្មោះនេះ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងទាស់លេខ២១ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០០១ របស់អ្នកស្រីកសវណេវ តាមពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី០៩-០៤-២០០១) ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ៣៤ (ឈ) ចុះថ្ងៃទី២៩ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍លើសេចក្ដីវិនិច្ឆ័យទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៦ខែកក្កដា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១- ទទួលបណ្ដឹងទាស់ ចុះថ្ងៃទី០៩-០៤-២០០១ របស់អ្នកស្រី កែវ សុវណ្ណវុធ ទុកជាត្រឹម ត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់ និងគតិច្បាប់

២-តម្កល់សាលដីការដ្ឋប្បវេណី កំបាំងមុខលេខ៣៤(ឈ) ចុះថ្ងៃទី២៩-០៣-២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូលដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី និងមេធាវីរបស់គូក្ដីបើកផ្លូវសាទុក្ខក្នុងរយៈពេល២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៣០១ ចុះថ្ងៃទី០៤ខែកញ្ញាឆ្នាំ២០០១ របស់លោកអយ ប្ដឹងមិនសុខចិត្ត ពីសាលាដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើចំណុចដែលមិនបានសម្រេច អំពីសំណងអន្តរាយ និងការខាតបង់ពេលវេលា និងបណ្ដឹងសាទុក្ខលេខ៣០០ ចុះថ្ងៃទី០៣ខែកញ្ញា ឆ្នាំ២០០១ របស់អ្នកស្រី កសវណេវ លើត្រង់ចំណុច នៃសេចក្ដីវិនិច្ឆ័យទាំងមូល ។

បានឃើញ សារណារបស់ អ្នកស្រី កែវ សុវណ្ណវុធ និង សារណារបស់លោក អយ

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ

បណ្ដឹងសាទុក្ខលេខ៣០០ ចុះថ្ងៃទី០៣-០៩-២០០១ និងបណ្ដឹងសាទុក្ខលេខ៣០១ ចុះថ្ងៃទី០៤-០៩-២០០១ របស់ចុងចម្លើយ ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

គូភាគី សុទ្ធតែបានរស់នៅលើដី និងផ្ទះទំនាស់នេះដូចគ្នាតាមអនុក្រឹត្យលេខ២៥ អនក្រ ចុះថ្ងៃទី២២-០៤-៨៩ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យពិចារណា ។

បានស្ដាប់ចម្លើយរបស់អ្នកស្រីកសវណេវ ឆ្លើយថា ខ្លួនមានការបំភ្លឺរបស់អភិបាលក្រុង ដោយមន្ត្រីសាលាក្រុង បានមកមើលផ្ទាល់ដល់ផ្ទះខ្លួនហើយលោក អយ មានផ្ទះច្រើនហើយនៅតែលោភលន់យកផ្ទះនិងដីខ្លួនទៀតផ្ទះ និងដីនេះខ្លួននៅតាំងពីឆ្នាំ៨០ ដល់១៩៩៤ ទើបមកប្ដឹងខ្លួន អយ ចង់វាតយកដីទាំ

ងអស់ យកទាំងដីក្នុងផ្ទះខ្លួនទៀត ឱ្យខ្លួនរស់នៅយ៉ាងដូចម្តេចកើត ខ្លួននៅនេះដោយមានការយល់ព្រមពីរដ្ឋអំណាចប្រគល់ឱ្យ។ អយ តែងតែប្រើអំពើហឹង្សាដល់រូបខ្លួន សូមតុលាការ កំពូល មេត្តារកយុត្តិធម៌ ព្រោះគេចេះតែពាមរករឿងខ្លួន រហូត ។

បានស្តាប់ចម្លើយរបស់លោក អយ ឆ្លើយថា ការលើកឡើងរបស់ចុងចម្លើយពេលនេះ គឺមិនពិតទេ ព្រោះចុងចម្លើយបានមកសុំផ្ទះខ្លួននៅ តែបីខែទេ ក្រោយមកមិនចេញដោយសារគេមានកងលាំងទាហានបានរួមគ្នា ប្រើអំពើហឹង្សាលើរូបខ្លួន ហើយប្រុងសំលាប់ខ្លួនទៀត

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក............ បញ្ជាក់ថាដីទំនាស់នេះកើតឡើងដោយសារការបែងចែករបស់រដ្ឋអំណាច ផ្ទះ និងដីនេះ កូនក្តីខ្ញុំចូលកាន់កាប់មុនអនុក្រិត្យលេខ២៥អនក្រចេញទៅទៀត ហេតុនេះ កូនក្តីខ្ញុំកាន់កាប់ផ្ទះ និងដីនេះស្របតាមច្បាប់ ។ សូមតុលាការកំពូល ពិចារណា និងរក្សាទុកឱ្យកូនក្តីខ្ញុំ បានរស់នៅលើផ្ទះនេះ តទៅ និងសុំលើកយកឯកសាររបស់សាលាក្រុងធ្វើ ជាមូលដ្ឋានស្របតាមអនុក្រិត្យលេខ២៥ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក ........... បញ្ជាក់ថា ផ្ទះលេខ១៤៧Eo នេះគឺស្ថិតក្នុងប្លុកមន្ទីរពេទ្យ៧មករា ប្រធានមន្ទីរពេទ្យបានឱ្យលោក អយ កាន់កាប់គ្រប់គ្រងរស់នៅពេលរដ្ឋអំណាចរកផ្ទះបានឱ្យឈ្មោះ កសវណរ មិនព្រមចេញទៅនៅទេ បែរជាមកបំពាននៅលើផ្ទះ ៖ដីទំនាស់ទៅវិញ ។ កាលមកសុំនៅដំបូងថា សុំដាក់ឥវ៉ាន់ជាបណ្តោះអាសន្នទេ ក្រោយមកក៏វាទយកដីរបស់កូនក្តីខ្ញុំឈ្មោះ អយ នេះធ្វើឱ្យកូនក្តីខ្ញុំប្តឹងហូរហែរជារហូតមក ។ បើតុលាការពិនិត្យមើលឯកសារឃើញថា ចម្លើយរបស់ចុងចម្លើយមុនឆ្នាំ១៩៩៦ ឆ្លើយថាខ្លួននៅលើផ្ទះនេះជាបណ្តោះអាសន្នទេក្រោយឆ្នាំ ១៩៩៦ មកចម្លើយរបស់ឈ្មោះកែវ សុវណ្ណវុធ ឆ្លើយផ្សេង ហើយរដ្ឋអំណាចបែរជាកាន់ជើងចុងចម្លើយទៅវិញ ដោយសារមានការណែនាំពីគេ ។សូមតុលាការកំពូលរក្សាសាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការតទៅ និងទាមទារជម្ងឺចិត្តពីចុងចម្លើយចំនួន២០០០០ដុល្លារ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវី នៃគូភាគី

-ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣០០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០១ របស់អ្នកស្រីកសវណរ និងបណ្តឹងសាទុក្ខលេខ៣០១ ចុះថ្ងៃទី០៤-០៩-២០០១ របស់អយ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ ដល់អង្គសេចក្តីបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការ តាំង

និងសកម្មភាពរបស់សាលាជំរះក្តី និងតាមមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្ត បានក្នុងរឿងរដ្ឋប្បវេណី ផងដែរ ។

-យល់ឃើញថា ការដែលអ្នកស្រី កសវណរ លើកឡើងក្នុងសារណា ចុះថ្ងៃទី១៧-០១-០២ ថា អ្នកស្រីត្រូវបាន រដ្ឋអំណាចមូលដ្ឋានប្តូរឱ្យមកនៅលើផ្ទះទំនាស់លេខ ១៧៤Eo ទាំងមូលតាំងពីឆ្នាំ១៩៨០ ដោយមានសាក្សី រដ្ឋអំណាច និងអង្គភាពជំនាញទទួលស្គាល់ ធ្វើឲ្យអ្នកស្រី មានសិទ្ធិលើផ្ទះទំនាស់លេខ ១៧៤Eo ទាំងមូល តាមមាត្រា១, ៤, ៥, ២៩,៣៨ និង មាត្រាដទៃទៀតនៃច្បាប់ភូមិបាលនោះ គឺជា ការភ័ន្តច្រឡំ ពីព្រោះថា នៅឆ្នាំ១៩៨០ ដែលអ្នកស្រី ចូលមករស់នៅផ្ទះលេខ១៧៤Eo នេះគឺរស់នៅតែ មួយបន្ទប់ផ្នែកខាងជើង ដែលបន្ទប់នេះក៏លោកអយ បានកាន់កាប់តាំងពីឆ្នាំ ១៩៧៩ រួចមកហើយ ហើយ នៅឆ្នាំ១៩៩០ ទើបអ្នកស្រីពង្រីកបន្ថែមបន្ទប់មួយ នៅខាងត្បូងនិងនៅឆ្នាំ ១៩៩៣ អ្នកស្រី ក៏ពង្រីកសាង សង់រោងលើដីចំណីផ្ទះ ផ្នែកខាងត្បូងទៀតដែលបន្ទប់ និងដីនេះលោកអយ បានកាន់កាប់រួចហើយដែរ ។ ជាក់ស្តែងអ្នកស្រីក៏បានឆ្លើយទទួលស្គាល់ នៅក្នុងកំណត់ហេតុផ្សះផ្សាសំរុះសំរួលនៅថ្ងៃទី០៦-៣-៩៦និង នៅថ្ងៃទី៣១-៧-៩៦មុខតុលាការក្រុងភ្នំពេញថានៅឆ្នាំ១៩៨០ នគរបាល បាននាំអ្នកស្រីមកនៅផ្ទះ ទំនាស់ជាបន្ទប់ថ្មដែលមានទំហំ៤ម x ១២ម ដោយគេប្រាប់ថា ឱ្យនៅបណ្តោះអាសន្នទំរាំរកផ្ទះបាន ហើយលោកអយ មិនឱ្យអ្នកស្រីនៅដែរ ប៉ុន្តែដោយ នគរបាលនិយាយជាមួយលោក អយ ទើបអ្នកស្រីបាន នៅ ។ ក្រោយមកមិនចំផ្គុំពេលមាន លោក អយ ងាប់អស់ អ្នកស្រីក៏បាំងបន្ទប់ថ្ម និងធ្វើសៀមនៅផ្នែកខាង ត្បូងទៀត ។

-យល់ឃើញថា អ្នកស្រី កសវណរ បានមករស់នៅ និងមានសិទ្ធិតែទៅលើផ្ទះលេខ១៧៤Eo មួយ បន្ទប់ក៏ពិតមែន ប៉ុន្តែនៅពេលដែលតុលាការក្រុងភ្នំពេញ សម្រេចបែងចែកផ្ទះលេខ១៧៤Eoនេះ និងដី ចំណីផ្ទះឱ្យគូភាគីរួចហើយ ដើមចោទពុំបានប្តឹងឧទ្ធរណ៍ទេ ដូច្នេះអ្នកស្រីកសវណរ ត្រូវបានទទួលផ្ទះ និង ដីទំនាស់នេះ តាមសាលក្រមរបស់តុលាការក្រុងភ្នំពេញដែរ ។

-យល់ឃើញថា ការដែលលោក អយ ប្តឹងសាទុក្ខជាលើកទី២ សុំទាមទារសំណងការខូចខាតនានា និងសុំរក្សាសភាពផ្ទះ១ល្វែង, សុំរៀបជញ្ជាំង, រៀបឥដ្ឋបិទបង្អួច និងឥដ្ឋឲ្យល់ ដូចសភាពដើមមុនឆ្នាំ ១៩៨៨ ទោះតុលាការកំពូលពុំអាចលើកមកពិចារណានិងសម្រេចបានឡើយ ពីព្រោះលោកពុំបានប្តឹង ទាមទារនៅតុលាការជាន់ទី១ទេ ហើយការទាមទារឲ្យរក្សាភាពដើមផ្ទះ ១ល្វែង សុំរៀបឥដ្ឋ ជញ្ជាំង, បិទ បង្អួច និងឥដ្ឋខ្យល់នោះ មន្ត្រីអនុវត្តសាលដីកាមានសមត្ថកិច្ចអនុវត្តពេញទីតាមខ្លឹមសារនៃសាលដីកា របស់សាលាឧទ្ធរណ៍ ដែលតុលាការកំពូលតម្កល់ទុកជាបានការហើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១០៤(ឈ) ចុះថ្ងៃទី២៦ខែ កក្កដា ឆ្នាំ២០០១ របស់ សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

<u>ហេតុដូច្នេះ</u>

**វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី**

១- ទទួលបណ្ដឹងសាទុក្ខលេខ៣០០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០១ របស់អ្នកស្រី កសវណេរ និងទទួលបណ្ដឹងសាទុក្ខលេខ៣០១ ចុះថ្ងៃទី០៤ ខែកញ្ញាឆ្នាំ ២០០១ របស់លោក អយ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១០៤(ឈ)ចុះថ្ងៃទី២៦ខែកក្កដា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន៣៨.០០០រៀល ដែលលោក អយ បានបង់គឺ

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០០រៀលសម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល នៅសល់ ១៩០០០រៀ បង្វិលឲ្យលោកអយ វិញ ហើយតម្រូវឲ្យអ្នកស្រីកសវណេរ សងប្រាក់៩៥០០រៀល ទៅលោក អយ ។

បង្គាប់ឱ្យគូភាគី បង់ពន្ធសមាមាត្រម្នាក់ៗ១% លើតម្លៃពាក់កណ្ដាលនៃដីនិងផ្ទះទំនាស់លេខ ១៧៤Eo ទាំងមូល ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២ ។